# របាយការណ៍ស្តីពីចុះពិនិត្យតាមដាន និងអភិបាលការងារផ្តល់សេវាបង្ការ
# និងថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ
# នៅគ្លីនិកសុខភាពគ្រួសារ មណ្ឌល១ ខេត្តសៀមរាប

**<u>ទីកន្លែង:</u>**

- គ្លីនិកសុខភាពគ្រួសារ មណ្ឌល ១ ខេត្តសៀមរាប ។

**<u>កាលបរិច្ឆេទ:</u>**

- ពីថ្ងៃទី ៩ ដល់ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១០ ។

**<u>មន្ត្រីចុះបេសកកម្ម:</u>**

- វេជ្ជ. ផល សាណូ ប្រធានផ្នែកគ្រប់គ្រងព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ
- វេជ្ជ. ចាន់ វិចិត្រ ប្រធានគ្លីនិកជាតិ សើស្បែក និងកាមរោគ
- លោក ញ៉េប ស៊ីម៉ុង មន្ត្រីមន្ទីរពិសោធន៍នៃគ្លីនិកជាតិ សើស្បែក និងកាមរោគ
- លោក ខែម ម៉ៅ អ្នកបើកបរ

**<u>គោលបំណង:</u>**

១-ពិនិត្យតាមដាន និង ផ្តល់ជំនួយលើផ្នែកបច្ចេកទេសដល់បុគ្គលិកបំរើការងារសេវានៅគ្លីនិកកាមរោគ និងពិនិត្យវាយតំលៃទៅលើលទ្ធភាពនៃការរៀបចំមន្ទីរពិសោធន៍សំរាប់សេវានេះ ។

២-ដោះស្រាយនូវបញ្ហា និងសំណូមពរមួយចំនួនដែលមាននៅក្នុងគ្លីនិកកាមរោគ ទៅតាមលទ្ធភាពដែលអាចធ្វើបានព្រមទាំងស្វែងរកតំរូវការបន្ថែមដើម្បីជំរុញអោយសេវាថែទាំជំងឺនៅគ្លីនិកកាមរោគដំណើរការបានល្អ និងមានប្រសិទ្ធភាព ។

**<u>លទ្ធផលនៃសកម្មភាពការងារ:</u>**

**១- ស្ថានភាពទូទៅ :**

- គ្លីនិកសុខភាពគ្រួសារខេត្តសៀមរាបគឺ ជាគ្លីនិកដែលមានទីតាំងស្ថិតនៅក្នុងមណ្ឌលសុខភាព មណ្ឌល១។
- គ្លីនិកនេះចែកចេញជា ៤ ផ្នែកសំខាន់ៗ គឺ :
    - បន្ទប់ពិនិត្យជម្ងឺស្ត្រី ២ បន្ទប់
    - បន្ទប់សំរាប់ពិនិត្យជម្ងឺបុរស ១ បន្ទប់
    - ផ្នែកស្រង់ប្រវត្តិជម្ងឺស្ត្រី
    - ផ្នែករង់ចាំ

- គ្លីនិកនេះផ្តល់សេវាស្ត្រីបំរើសេវាកំសាន្តសប្បាយដោយផ្ទាល់ និងប្រយោលតាមពេលម៉ោងធ្វើការរបស់រដ្ឋ រួមទាំងការផ្តល់សេវាជូនដល់ស្ត្រីទូទៅ ត្រូវមកទទួលសេវានៅគ្លីនិកនេះដែរ ។
- គ្លីនិក រួមទាំងបុគ្គលិកទាំងអស់ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់មណ្ឌលសុខភាព មណ្ឌល ១ ខេត្តសៀមរាប ។
- អាគារគ្លីនិក មានរៀបចំជាបន្ទប់រង់ចាំ និងបន្ទប់ពិនិត្យជម្ងឺស្ត្រីដាច់ដោយឡែកពីគ្នា ក៏ប៉ុន្តែការស្រង់ប្រវត្តិជម្ងឺមិនអាចរក្សាការសំងាត់បានត្រឹមត្រូវនៅឡើយ ដោយសារការស្រង់ប្រវត្តិជម្ងឺនេះធ្វើឡើងនៅបន្ទប់រួមគ្នាជាប់នឹងបន្ទប់ពិនិត្យជំងឺ ។
- មានទូរទស្សន៍និងម៉ាស៊ីន VCD មួយគ្រឿងសំរាប់ប្រើប្រាស់អប់រំអតិថិជននៅបន្ទប់រង់ចាំ បញ្ជី ឯកសារបញ្ជីសំរង់ពតិមានអ្នកជម្ងឺ និង បណ្ណ័វិភាគនានា មានប្រើប្រាស់គ្រប់គ្រាន់ និងរៀបចំទុកដាក់បានត្រឹមត្រូវ ។
- ឪសថមានប្រើប្រាស់គ្រប់គ្រាន់ ។
- ស្ត្រីបំរើសេវាកំសាន្តសប្បាយដោយផ្ទាល់និងដោយប្រយោលត្រូវបានបញ្ជូនមកពិនិត្យជាទៀងទាត់រៀងរាល់ខែដោយក្រុមអប់រំផ្ទាល់/មិត្តអប់រំមិត្តរបស់អង្គការ CWPD, MHC ។
- បន្ទាប់ពីដាក់អោយប្រើប្រាស់ SOP ថ្មីនៅត្រីមាសទី២ ឆ្នាំ២០០៩បានជួយលើកទឹកចិត្តនិង ជំរុញអោយ EWs និង MSM មកពិនិត្យមានការកើនឡើង ប៉ុន្តែចំនួនស្ត្រីរកស៊ីផ្ទាល់មានការថយចុះ ដោយសារស្ត្រីទាំងនោះ បានប្តូររូបភាពរកស៊ី និងដោយសារការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរផ្លូវភេទ។ ចំពោះការបញ្ជូនស្ត្រីធ្វើការនៅសេវាកំសាន្តក្រៅផ្ទះបន មិនសូវបានទៀងទាត់ដូចស្ត្រីនៅតាមផ្ទះបនទេ។

## ២. ផ្នែកសេវាថែទាំជំងឺកាមរោគ

<u>ការស្រង់ប្រវត្តិអ្នកជម្ងឺ :</u>

- ការស្រង់ប្រវត្តិអ្នកជម្ងឺ ធ្វើឡើងដោយមន្ត្រីគ្លីនិកទាំងអស់ ដោយមិនមានបែងចែកការងារនេះដាច់ដោយឡែកសំរាប់ម្នាក់ៗទេ ។ ការសាកសួរនេះមិនអាចរក្សាការសំងាត់បានល្អត្រឹមត្រូវគ្រប់ទាំងអស់បានទេ ដោយសារតែគ្មានបន្ទប់ខណ្ឌ័ដាច់ដោយឡែកសំរាប់ការសាកសួរនេះ ។ ការសាកសួរប្រវត្តិជម្ងឺនេះ ធ្វើឡើងចំពោះគ្រប់ករណីជម្ងឺទាំងអស់ ក៏ប៉ុន្តែមានពេលខ្លះអាចមិនបានគ្រប់ជ្រុងជ្រោយ១០០%បានឡើយដោយសារពេលវេលាមិនមានគ្រប់គ្រាន់ ។
- ដោយឡែកការពិនិត្យជម្ងឺ គឺធ្វើឡើងនៅក្នុងបន្ទប់ដែលបិទជិតអាចរក្សាការសំងាត់បានយ៉ាងល្អត្រឹមត្រូវ ។

<u>ការពិនិត្យអ្នកជម្ងឺ :</u>

- នៅក្នុងបន្ទប់ពិនិត្យជម្ងឺ មានបំពាក់សំភារៈ ដូចជាគ្រែពិនិត្យជម្ងឺ, អំពូលភ្លើងសំរាប់បញ្ចាំងពន្លឺ, កៅអី និងបរិក្ខាផ្សេងៗទៀត គ្រប់គ្រាន់សមល្មមប្រើការបានត្រឹមត្រូវតាមបច្ចេកទេស ប៉ុន្តែបន្ទប់ទាំងនោះមានសភាពតូចចង្អៀត ដោយសារការខណ្ឌ័បែងចែកជា ២ បន្ទប់ជាប់គ្នា។
- ការព្យាបាលគឺផ្អែកទៅលើគោលការណ៍ណែនាំរបស់ជាតិ សំរាប់ការពិនិត្យ និងព្យាបាលជម្ងឺកាមរោគដោយពឹងផ្អែកលទ្ធផលតេស្តមន្ទីរពិសោធន៍ ។

- ចំពោះការពិនិត្យគ្លីនិក (ពិនិត្យទូទៅ មាត់ ប្រដាប់ភេទ) ពុំទាន់អនុវត្តទៅតាមបច្ចេកទេសឱ្យបានហ្មត់ចត់នៅឡើយទេ ដោយសារបញ្ហាពេលវេលា ។
- ការពិនិត្យដោយស្ពេគូឡូម ជាទូទៅអនុវត្តនៅលើស្ត្រីបំរើសេវាកំសាន្តសប្បាយ ហើយមានស្ពេគូឡូមគ្រប់គ្រាន់សំរាប់ប្រើប្រាស់ ដោយមានការផ្គត់ផ្គង់ពីអង្គការសុខភាពគ្រួសារអន្តរជាតិ ។
- ការស្រង់វត្ថុវិភាគដើម្បីបញ្ជូនទៅវិភាគរកមេរោគនៅមន្ទីរពិសោធន៍ គឺបានធ្វើនៅលើគ្រប់ស្ត្រីបំរើសេវាកំសាន្តសប្បាយដែលបានមកពិនិត្យនៅគ្លីនិក ។

<u>ការធ្វើរោគវិនិច្ឆ័យ :</u>

- ការស្រង់វត្ថុវិភាគដើម្បីបញ្ជូនទៅវិភាគរកមេរោគនៅមន្ទីរពិសោធន៍ គឺបានធ្វើតែនៅលើគ្រប់ស្ត្រីបំរើសេវាកំសាន្តសប្បាយទាំងអស់ ។
- ដោយឡែកការពិនិត្យតាមការស្ទាបផ្នែកខាងក្រោមនៃពោះរួមនឹងការលូកទ្វារមាស មិនបានអនុវត្តលើគ្រប់ករណីជម្ងឺនៅឡើយទេ ។
- ចំពោះការស្រង់វត្ថុវិភាគចំពោះអ្នកជម្ងឺបុរស គឺមិនបានធ្វើទេ ដោយសារគ្មានការផ្គត់ផ្គង់សំឡីត្បារសំរាប់បុរសពីមជ្ឈមណ្ឌលជាតិ ។

<u>ការព្យាបាល :</u>

- ការព្យាបាល គឺធ្វើទៅតាមគោលការណ៍ណែនាំជាតិ បានត្រឹមត្រូវ ។
- បុគ្គលិក គ្លីនិកកាមរោគតែងតែបានពន្យល់ឱ្យអ្នកជម្ងឺបានដឹងពីការប្រើប្រាស់ឱសថត្រឹមត្រូវ ទៀងទាត់ និងខ្ជាប់ខ្ជួន ព្រមទាំងពន្យល់អំពីផលវិបាកខ្លះៗនៃឱសថព្យាបាលផងដែរ ។
- គ្រប់អតិថិជនដែលមកទទួលសេវាថែទាំព្យាបាលនៅគ្លីនិកកាមរោគតែងតែត្រូវបានទទួលការអប់រំណែនាំ និងជូនដំណឹងអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។ លក្ខណៈពិសេសនៅគ្លីនិកសុខភាពគ្រួសារនេះគឺ មណ្ឌលធ្វើតេស្តឈាមស្ថិតនៅជាមួយគ្នានឹងគ្លីនិក និងមន្ទីរពិសោធន៍កាមរោគ ។
- បញ្ហាដែលគួរឱ្យកត់សំគាល់ គឺ គ្លីនិកកាមរោគខេត្តតែងតែផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រីបំរើសេវាកំសាន្តសប្បាយតែប៉ុណ្ណោះ ដោយពុំបានផ្តល់សេវានេះឱ្យបានទូលំទូលាយនៅឡើយទេ ដូចជាការធ្វើតេស្តមន្ទីរពិសោធន៍ដើម្បីធ្វើរោគវិនិច្ឆ័យជាដើម ។

<u>ការហៅដៃគូរួមភេទឱ្យមកទទួលការព្យាបាល :</u>

- ជាទូទៅមានការលំបាក ជាពិសេសដោយសារតែអតិថិជនរបស់គ្លីនិកភាគច្រើនជាស្ត្រីបំរើសេវាកំសាន្តសប្បាយ ។
- ចំពោះបណ្ណ័អញ្ជើញដៃគូឱ្យមកទទួលការព្យាបាលពុំទាន់មាន ផ្តល់ពីមជ្ឈមណ្ឌលជាតិ នៅឡើយទេ ។

## របាយការណ៍ស្តីអំពីលទ្ធផលនៃការព្យាបាលជំងឺកាមរោគនៅគ្លីនិកសុខភាពគ្រួសារ
## ត្រីមាសទី ១_២០១០

| | | ខែទី១ | ខែទី២ | ខែទី៣ |
|---|---|---|---|---|
| ចំនួនសរុបនៃការពិនិត្យអ្នកជំងឺបុរស | ចំនួនបុរសសរុបទាំងអស់ | ១៩ | ៤៣ | ១៩ |
| | ចំនួន MSM | ១២ | ២៦ | ៩ |
| ចំនួនសរុបនៃការពិនិត្យអ្នកជំងឺស្ត្រីដែលមានការប្រឈមមុខទាប | | ១៨៧ | ២៣៥ | ២០២ |
| ចំនួនសរុបនៃការពិនិត្យលើកដំបូង សំរាប់ស្ត្រីបំរើសេវាកំសាន្ត (EW) | | ៩៥ | ៧៣ | ៧៣ |
| ចំនួនសរុបនៃការពិនិត្យតាមដានបន្ត សំរាប់ស្ត្រីបំរើសេវាកំសាន្ត (EW) | | ៣៦ | ៤៣ | ៣៣ |
| ចំនួនសរុបនៃការពិនិត្យលើកដំបូង សំរាប់ស្ត្រី រកស៊ីផ្លូវភេទដោយផ្ទាល់ ផ្ទះបន | | ៥ | ៨ | ១ |
| ចំនួនសរុបនៃការពិនិត្យតាមដានបន្ត សំរាប់ស្ត្រី រកស៊ីផ្លូវភេទដោយផ្ទាល់ ផ្ទះបន | | ៣៦ | ៣២ | ២៣ |
| ចំនួនសរុបនៃ ស្ត្រីបំរើសេវាកំសាន្ត ដោយបណ្តាញស្ត្រី (CWPD & MHC) | | ១៣១ | ១១៦ | ១០៦ |
| ចំនួនសរុបនៃ ស្ត្រី រកស៊ីផ្លូវភេទដោយផ្ទាល់ ដោយបណ្តាញស្ត្រី (CWPD & MHC) | | ៤១ | ៤០ | ២៤ |

| | ខែទី១ | ខែទី២ | ខែទី៣ |
|---|---|---|---|
| ចំនួនសរុបនៃអ្នកជំងឺ ដែលបញ្ជូន ពី គ្លីនិក សុខភាពគ្រួសារ ទៅ VCCT | ២៨ | ២៦ | ១៣ |
| ចំនួនសរុបនៃអ្នកជំងឺ ដែលបញ្ជូនអតិថិជន ពី គ្លីនិក សុខភាពគ្រួសារ ទៅពិនិត្យផ្ទៃពោះ | 0 | 0 | 0 |
| ចំនួនសរុបនៃអ្នកជំងឺ ដែលបញ្ជូន ពី គ្លីនិក សុខភាពគ្រួសារ ទៅ សេវាពន្យាកំណើត | 0 | 0 | 0 |

### ផ្នែកមន្ទីរពិសោធន៍ :

**ស្ថានភាពទូទៅ:**

មន្ទីរពិសោធន៍ជំងឺកាមរោគ ស្ថិតនៅក្នុងមណ្ឌលសុខភាព មណ្ឌល១ នៃទីរួមខេត្តសៀមរាប ហើយបានរួមបញ្ចូលគ្នាជា មួយមន្ទីរ ពិសោធន៍ VCCT ផងដែរ។ មន្ទីរពិសោធន៍នេះ មានដំណើរការល្អ ផ្តល់ភាពងាយស្រួលដល់អតិថិជន ក្នុងការទៅរកសេវាមន្ទីរពិសោធន៍។

**បុគ្គលិក:**

១- លោក ញ៉ុក វិសិដ្ឋ បំរើការផ្នែក STD+VCCT ជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍ ធ្លាប់បានឆ្លងវគ្គមន្ទីរពិសោធន៍ជំងឺកាមរោគ

២- លោកស្រី ហ៊ីង ណារុំ បំរើការផ្នែក STD+VCCT ជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍ ធ្លាប់បានឆ្លងវគ្គមន្ទីរពិសោធន៍ជំងឺកាមរោគ

**តេស្តមន្ទីរពិសោធន៍:**

1- Saline Wet Mount
2- Gram stain for vaginal smear (for Bacterial Vaginosis)
3- Methylene blue for endocervical smear
4- RPR test (qualitative only)
5- Syphilis rapid test is available

ផ្នែកដែលបានរៀបរាប់ក្នុងតេស្តមន្ទីរពិសោធន៍ មានដំណើរការល្អ។ ចំណែកឯ Gram stain for Urethral smear ក៏ពុំដែលបានធ្វើដែរ ដោយគ្លីនិកនេះ ពុំទាន់មាន Swab សំរាប់ពិនិត្យកាមរោគលើបុរស។

**ការអនុវត្តការប្រុងប្រយ័ត្នជាសាកល:** បានល្អ ពុំមានបញ្ហាទេ ។

**ប្រតិករ និងសម្ភារ:**

ប្រតិករ និង សម្ភារៈត្រូវបានផ្គត់ផ្គង់ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក-កាមរោគ។

ការថែរក្សា ប្រតិករ បានល្អ ពុំមានបញ្ហាទេ ។

កាលៈបរិច្ឆេទប្រើប្រាស់ (expiry date) : ត្រឹមត្រូវ ។

សម្ភារៈដែលខ្វះខាតមាន:

- Microscope lens cleaning paper
- Microscope lens cleaning paper

**សំណូមពរពីបុគ្គលិក:**

សូមរៀនវគ្គបំប៉នផ្នែកមន្ទីរពិសោធន៍កាមរោគបន្ថែមទៀត ។

**ដំណោះស្រាយ:**

- គួរអញ្ជើញមន្ត្រីផ្នែកមន្ទីរពិសោធន៍កាមរោគ មកចូលរួមវគ្គបំប៉ន ។
- គួរបើកទូលាយឱ្យពិនិត្យជំងឺកាមរោគនិងតេស្ត មន្ទីរពិសោធន៍លើប្រជាជនទូទៅ ។
- ផ្គត់ផ្គង់សម្ភារៈដែលខ្វះខាតដល់មន្ទីរពិសោធន៍នេះ ។

**សំណូមពរដើម្បីធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់សេវានៅគ្លីនិកសុខភាពគ្រួសារ**

- ពង្រឹង និងបន្ថែមនូវចំណេះដឹងថ្មីៗដល់បុគ្គលិកគ្លីនិកតាមរយៈការបណ្តុះបណ្តាលបំប៉នរៀងរាល់ឆ្នាំ ។
- ផ្តល់ Urethral swap សំរាប់ការស្រង់វត្ថុវិភាគលើបុរសដែលសង្ស័យមានឆ្លងមេរោគ Gonococcus & Chlamydia ។
- រៀបចំកែលំអរគ្លីនិកឱ្យសមស្របជាគ្លីនិកគំរូ ជាពិសេសការរៀបចំបន្ទប់ស្រង់ប្រវត្តិជម្ងឺ និងបន្ទប់អប់រំផ្តល់ប្រឹក្សា ឱ្យនៅដាច់ដោយឡែក និងរក្សាការសំងាត់ និងបន្ទប់ពិនិត្យជម្ងឺឱ្យមានភាពធំទូលាយ ។
- ផ្តល់សំភារៈមន្ទីរពិសោធន៍ដែលខ្វះខាតមាន:
    - Microscope lens cleaning paper
    - Microscope lens cleaning solution
- បំប៉នសមត្ថភាពមន្ត្រីផ្នែកមន្ទីរពិសោធន៍កាមរោគបន្ថែមទៀត តាមរយៈការធ្វើកម្មសិក្សាផ្នែកមន្ទីរពិសោធន៍ជាពិសេស ការសំរួលដល់មន្ត្រីមន្ទីរពិសោធន៍នេះដែលត្រូវទទួលភារកិច្ចបន្ថែមទៀតចំពោះការធ្វើតេស្តរកមេរោគអេដស៍គ្រប់សំណាកឈាមដែលបញ្ជូនមកពី Linked health centers ។

ភ្នំពេញ, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១០

បានឃើញ

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

វេជ្ជ មាន_ឈីវុន

ក្រុមការងារអភិបាល

វេជ្ជ. ផល សាណូ